ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

គាំពារសង្គមកម្ពុជា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៨៩)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៣ ២២៣នាក់ នៃសហគ្រាសទាំង៣៣ នៃវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលសហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅសហគ្រាសទាំង៣៣ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលសហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករសហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ១០កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២៣

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

## ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣

## បញ្ជីឈ្មោះ សហគ្រាស ក្នុងវិស័យទេសចរណ៍
## ចំនួន ៣៣ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះសហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| វិស័យទេសចរណ៍ | | 33 |
| 1 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 2 | សណ្ឋាគារ ស្ទឹងសៀមរាបថ្មី | សៀមរាប |
| 3 | សណ្ឋាគារ គូលែន | សៀមរាប |
| 4 | សណ្ឋាគារ ខ្មែរអង្គរហូថែលកូអិលធីឌី | សៀមរាប |
| 5 | សណ្ឋាគារ ខេមរាអង្គរ | សៀមរាប |
| 6 | សណ្ឋាគារ វីចេនស៊ីអង្គរ | សៀមរាប |
| 7 | សណ្ឋាគារ អង្គរ | សៀមរាប |
| 8 | សណ្ឋាគារ ម៉េម៉័រអង្គរ (ខេមបូឌា) | សៀមរាប |
| 9 | សណ្ឋាគារ គោព្រៃ | សៀមរាប |
| 10 | សណ្ឋាគារ ជាតិថាតា អង្គរ | សៀមរាប |
| 11 | សណ្ឋាគារ អង្គរ សេនជូរី គ្រុប ភីធីអ៊ី អែលធីឌី | សៀមរាប |
| 12 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 13 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 14 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 15 | សណ្ឋាគារ វិរតន៍ | សៀមរាប |
| 16 | សណ្ឋាគារ វិរតន៍ វីឡា | សៀមរាប |
| 17 | សណ្ឋាគារ សិន្តា មុន្នី | សៀមរាប |
| 18 | សណ្ឋាគារ អង្គរ ហូតែល គ្រុប(សណ្ឋាគារ អប្សរា ផាឡេស) | សៀមរាប |
| 19 | សណ្ឋាគារតាព្រហ្ម | សៀមរាប |
| 20 | សណ្ឋាគារ សាបារា អង្គរ រីសត និង ស្ប៉ា | សៀមរាប |
| 21 | សណ្ឋាគារ ស្វាយលីង | សៀមរាប |

| ល.រ | ឈ្មោះសហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 22 | សណ្ឋាគារសុខៈប៊ូទិក | សៀមរាប |
| 23 | សណ្ឋាគារ អង្គរតែលេសរីហ្សត និងស្ប៉ា | សៀមរាប |
| 24 | សណ្ឋាគារ យើងដុម អង្គរ | សៀមរាប |
| 25 | សណ្ឋាគារ អេមព្រីស អង្គរ | សៀមរាប |
| 26 | សណ្ឋាគារ បាយ័ន អេរ៉ា ហូថែល ខបភើរេសិន | សៀមរាប |
| 27 | សណ្ឋាគារ កាឡាស ខម (ខេមបូឌា) ភីធីអ៊ី អិលធីឌី (សណ្ឋាគារ អង្គរ អេរ៉ា) | សៀមរាប |
| 28 | សណ្ឋាគារសោមាទេវីអង្គររីសត & ស្ប៉ា | សៀមរាប |
| 29 | សណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និង ស្ប៉ា | សៀមរាប |
| 30 | សណ្ឋាគារ ប៉ារ៉ាឌីសអង្គរវីឡា | សៀមរាប |
| 31 | សណ្ឋាគារ សុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 32 | សណ្ឋាគារ ហ្គោលដេន ទ្រី ព្រីនស៍ ហូថែល និងស្ប៉ា | សៀមរាប |
| 33 | សណ្ឋាគារ ប៉ាស៊ីហ្វិក | សៀមរាប |